ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣១-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១៣៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្សាង ស៊ុនឌូ** (JANG SUNGDOO) ជនជាតិ កូរ៉េ សញ្ជាតិ កូរ៉េ កើតនៅស្រុកគុងណាម ខេត្តស៊ុងគុន សាធារណរដ្ឋកូរ៉េ	៣១៩៤
១១-៤-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៤២ ស្តីពីការបញ្ចប់មុខតំណែង ឯកឧត្តម **ឌា ជុំ** ពីទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី	៣១៩៥
១១-៤-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៤៣ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **គួច វណ្ណថា** ពីអនុមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងអភិវឌ្ឍន៍ជនបទ មកជាអនុមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ	៣១៩៦

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៨-៤-២០០៧	-អនុក្រឹត្យលេខ ៣១៩ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពតំណាង ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត	៣១៩៧
១៨-៤-២០០៧	-អនុក្រឹត្យលេខ ៣២០ អនក្រ.តត ស្តីពីការសម្រួលភារកិច្ចមន្ត្រីរាជការ	៣១៩៨
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣១៩៩
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣២០០
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣២០១
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣២០២
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣២០៣
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣២០៤

១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៣២០៥
១៩-៤-២០០៧	-អនុក្រឹត្យលេខ ៣២៨ អនក្រ.តត ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្មព្រែកលៀប	៣២០៧

២_សារាចរណែនាំ

១៣-៤-២០០៧	-សារាចរណែនាំលេខ០១ សរ ណន ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៨	៣២០៩

III_ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១០៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នែតវើល ប្រូដាក់ ណេតវើក**	៣២១៦
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១០៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មិញ ត្រាន អ៊ីមផត អិចផត**	៣២១៨
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១០៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេមតី ទ្រីម**	៣២២០
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១០៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិម & ឌី**	៣២២២
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ០១១៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស_សុភាព (ខេមបូឌា)**	៣២២៤
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១១៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង ហៃ អ៊ិនធើណេសិនណល ធួរ អេជេនស៊ី**	៣២២៦
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១១៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ជី.អេនើជី ខូអិលធីឌី**	៣២២៨
០៩-០១-២០០៧	-លិខិតបញ្ជាក់លេខ ០១១៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គ្រេន ស្ពេនឌើត**	៣២៣០

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ហ្សាង ស៊ុងដូ (JANG SUNGDOO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៥៧ នៅស្រុកគុងណាម ខេត្តកូស៊ុងគុន សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល.០៧០៣.១៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ [illegible]

លេខ: ១៥១ ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ០៧ ឆ្នាំ២០០៧
[illegible]រដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម ខាង ជួងពីទីប្រឹក្សាផ្ទាល់ ឯកឧត្តម ញ៉ឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

ពរល.០៧០៤.១៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៧

លេខ: ១៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌលោក តូច ចន្ធូថា ពីអនុមន្ត្រី ថ្នាក់លេខ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងអភិវឌ្ឍន៍ជនបទ មកជាអនុមន្ត្រី ថ្នាក់លេខ១០ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ១៧២៤.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

៣រល.០៧០៤.១៥៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៣២៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងសមាសភាពតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៦/៩៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពី ការដាក់មន្ទីរពេទ្យកាល់ម៉ែត ជា គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងឯកឧត្តម **ទឹម ទិសិដ្ឋ** សមាជិកក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី ជា **សមាជិកក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកាល់ម៉ែត** ជាថ្មីម្តងទៀត ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការសម្រួលភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា១ : ត្រូវបានសម្រួលភារកិច្ចលោក **ចំនួ សុខណ្ណារ៉េត** ពីអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ[illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣២១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកវរសេនីយ៍ឯក **អ៊ាច ចំរើន** ស្នងការនគរបាល ខេត្តកណ្តាល ដែលមានស្នាដៃល្អក្នុងការចូលរួមកសាងអភិវឌ្ឍន៍ប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកឧកញ៉ា **ថ្រី ហេង** ដែលបានបរិច្ចាគធនធាន ជួយសាងសង់អគារសិក្សា ចំនួន០៤ខ្នង និងសមិទ្ធផលជាច្រើនទៀត នៅវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី (អតីតវិទ្យាល័យសំរោងអណ្តែត) ចំណាយអស់ថវិកាសរុបចំនួន ២៨៣.២២៥ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២៣ . អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **តែ អៀងហួត** សប្បុរសជនខ្មែរនៅប្រទេសអូស្ត្រាលី ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយសាងសង់អគារសិក្សា ០១ខ្នង និងបំពាក់នូវសម្ភារៈ តុកៅអីសិស្ស នៅអនុវិទ្យាល័យព្រៃពួច ក្នុងឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ចំនួន ១៦.០០០ ដុល្លារ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២៤-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **សេ សាន** សប្បុរសជននៅទីក្រុងភ្នំពេញ ដែលបានបរិច្ចាគធនធានជួយកសាង អគារសិក្សា ចំនួន០១ខ្នង ស្រះទឹក សាលាភ័ត្ត និងសមិទ្ធផលមួយចំនួនទៀត នៅវត្តអង្គភ្នំតូច ក្នុងឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត ចំណាយអស់ទឹកប្រាក់សរុបចំនួន ៣០.៩០០ ដុល្លារ ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក WATANABE MIKI អគ្គនាយកអង្គការ School Aid Japan ដែលបានផ្តល់ថវិកា ចំនួន ២១.៦៦៣ ដុល្លារ សំរាប់សាងសង់អគារសិក្សា ០១ខ្នង អណ្តូងទឹក ០១ និង បង្គន់ ០២ នៅសាលាបឋមសិក្សាលំលេច ក្នុងឃុំលំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៦២ ...អនក្រ.ត.ស.ក-៩៩

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន០៤រូប ដែលបានឧបត្ថម្ភថវិកាជួយកសាង វិស័យអប់រំ នៅរាជធានីភ្នំពេញ ដូចមានខាងក្រោម :-

១-លោកស្រី **សូរាជ ស៊ីរីនីតា** នាយិកាប្រតិបត្តិ របស់ WDA
២-លោក ENRICO CAMPIGLIA នាយក INWA
លោកស្រី និងលោក ខាងលើ បានឧបត្ថម្ភថវិកា ចំនួន ១៤១.៩១៧ ដុល្លារ ជួយសាងសង់អគារសិក្សា ០១ខ្នង កំពស់ ០២ជាន់ មាន ១៤បន្ទប់ នៅសាលាបឋមសិក្សាច្បារអំពៅ ទី១ ។
៣-ព្រះតេជគុណ **សេ ឌួច** ចៅអធិការវត្ត អរុណវតី បានឧបត្ថម្ភដីទំហំ ៨.៨៨០ ម៉ែត្រការ៉េ គិតជាថវិកា ចំនួន ១៤.០០០ ដុល្លារ សំរាប់សាងសង់ អនុវិទ្យាល័យ ហ៊ុន សែន-ប៊ុន រ៉ានី អរុណវតី ។
៤- **Sister Regina** បានឧបត្ថម្ភថវិកា ចំនួន ២០.០០០ ដុល្លារ ជួយសាងសង់អគារសិក្សា ០១ខ្នង មាន ០៥ បន្ទប់ និង បង្គន់អនាម័យ ១០ បន្ទប់ នៅសាលាបឋមសិក្សាវត្តដំបូកខ្ពស់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ជួយកសាងសមិទ្ធផលផ្សេងៗ ផ្នែកពុទ្ធសាសនា អប់រំ និង សង្គមកិច្ច នៅឃុំផ្គាប្រជុំ ស្រុកកោះអណ្តែត ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **អ៊ូច ទិបុណ**	ចៅអធិការវត្តឈើទាលសំបូរ	បច្ច័យចំនួន១៩.០០០ ដុល្លារ
២-ឯកឧត្តម **ស៊ូ គីរិន្ទ**	សប្បុរសជននៅខេត្តសៀមរាប	ថវិកាចំនួន ១៥.០០០ ដុល្លារ
៣-លោកជំទាវ **និន សាផុន**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១៧.៥០០ ដុល្លារ
៤-លោក **ម៉ៅ ញ៉ឹន** និងអ្នកស្រី **នាង សារឹម**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ២១.០៥០ ដុល្លារ
៥-លោក **ឡឿម នូច**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ៦២.៦០០ ដុល្លារ
៦-លោក **ប៊ិច ប៊ុនឡឿន** និងអ្នកស្រី	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២២.៩០០ ដុល្លារ
៧-ឧបាសិកា **តែ គីមមួយ**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៦.៩០០ ដុល្លារ
៨-លោក **អ៊ួង ណារ៉េន** និងអ្នកស្រី	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១៣.៥០០ ដុល្លារ
៩-លោក **នាង សឿន** និងអ្នកស្រី	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១២.៩០០ ដុល្លារ
១០-លោក **សុខ សួន** និងអ្នកស្រី	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ

ខ_មេដាយសិរីវឌ្ឍនាជាតិ :

-លោកស្រី **លាន ស៊ីវហ៊ុន** ថវិកាចំនួន ៣.៨០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៤ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧២៧ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាល

ប្រចាំសាលាជាតិកសិកម្មព្រែកលៀប

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ស ម្រេ ច

មាត្រា ១ .-

ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលអាណត្តិទី២ ដែលមានសមាសភាពដូចខាងក្រោម :-

១- លោក	**ឡោ ស្មី**	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ប្រធាន
២- លោក	**ហាក់ ស៊ីណា**	តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី	សមាជិក
៣- លោក	**ម៉ី រិន**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤-លោកស្រី	**ម៉ក់ ណាង**	តំណាងក្រសួងអប់រំ យុវជន និងកីឡា	សមាជិកា
៥- លោក	**ផាត់ មុនី**	នាយកសាលាជាតិកសិកម្មព្រែកលៀប	សមាជិកស្វ័យប្រវត្តិ
៦- លោក	**អ៊ុក ស៊ីផាន**	ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធន៍	សមាជិក
៧- លោក	**ឈុត សុខោន**	តំណាងបុគ្គលិកសាលាជាតិកសិកម្មព្រែកលៀប	សមាជិកស្វ័យប្រវត្តិ

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១. សរាចរ

សារាចរណែនាំ

ស្តីពី

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៨

I. សេចក្តីផ្តើម

១- មាត្រា ២៦ ថ្មី នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ បានបែងចែកកិច្ចដំណើរការនៃការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែ មិនា ដល់ ខែ ឧសភា (២) *ដំណាក់កាលទី ២:* ការរៀបចំកញ្ចប់ថវិកា ពីខែ មិថុនា ដល់ ខែកញ្ញា និង *ដំណាក់កាលទី ៣:* ការអនុម័តថវិកា ពីខែ តុលា ដល់ ខែ ធ្នូ ។ ប្រការនេះ តំរូវអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសារាចរណែនាំពីរគឺ *សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា* ដែលត្រូវចេញនៅ ដើមខែ មេសា និង *សារាចរណែនាំស្តីពីការរៀបចំកញ្ចប់ថវិកា* ដែលត្រូវចេញនៅដើមខែ មិថុនា ។ ដូច្នេះ សារាចរនេះ មានគោលបំណងដើម្បីណែនាំ និង ធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ឆ្នាំ ២០០៨ ដល់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញគ្រប់ខេត្ត- ក្រុងទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកាអោយចំទិសដៅ និង បំរើអោយសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង- ស្ថាប័ន ក្នុងគោលដៅសំរេចអោយបាននូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង- ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ ដើម្បីរួមចំណែកសំរេចអោយបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តំរូវអោយក្រសួង- ស្ថាប័ននីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** រៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះគឺជាមូលដ្ឋានដ៏សំខាន់សំរាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតំរូវការថវិកា (៣) ជាមូលដ្ឋានសំរាប់ពន្យល់ និង ធ្វើអំណះអំណាងលើតំរូវការថវិកា និង ជាពិសេស (៤) គឺជាមូលដ្ឋានសំរាប់វាយតំលៃលើអាទិភាព ក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ដើម្បីអោយការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះអាចប្រព្រឹត្តទៅដោយរលូន និង គ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ ត្រូវអោយផ្សាភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង បញ្ចូលទាំងចំណាយចរន្ត និង មូលធន ព្រមទាំងថវិកាជាតិ និង ថវិកាជំនួយផងនោះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតក្រុមការងារថវិកា ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និង គណនេយ្យ នាយកដ្ឋានផែនការ និង គ្រប់អង្គភាពគ្រប់គ្រងគំរោង ។ ហើយក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង និង វិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នពិនិត្យ សំរេច និង ចុះហត្ថលេខា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបាន ***ត្រឹមថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧*** ដើម្បីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សំរាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួងសាមុីមកពិគ្រោះ និង សាកសួរពត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន ដែលផ្តល់ផែនការយុទ្ធសាស្ត្រថវិកាយឺត អាចធ្វើអោយប៉ះពាល់ដល់ការវិភាជន៍កញ្ចប់ថវិកាមិនបានសមស្របទៅនឹងអាទិភាពរបស់ខ្លួន ។

II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា

ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤- សេដ្ឋកិច្ចកម្ពុជា កំពុងតែវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការរីកធំធាត់ជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម នៅក្នុងរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប (ផសស) ។ ជាក់ស្តែង ក្នុងរយៈកាល ៧ ឆ្នាំកន្លងទៅនេះ សមាមាត្រនៃវិស័យទាំង ៣ នៃសេដ្ឋកិច្ចកម្ពុជាបានវិវត្តពី វិស័យកសិកម្មរួមចំណែកប្រមាណ ៣៦% វិស័យឧស្សាហកម្ម ២៧% និង វិស័យសេវាកម្ម ៣៧% នៅឆ្នាំ ២០០០ មកវិស័យកសិកម្មរួមចំណែកត្រឹម ៣២% វិស័យឧស្សាហកម្ម ២៦% និង វិស័យសេវាកម្ម ៣៧% នៅឆ្នាំ ២០០៦ ។ ទោះបីសមាមាត្រនៃវិស័យកសិកម្មនៅក្នុង ផសស ចាប់ផ្តើមធ្លាក់ចុះជាបន្តបន្ទាប់ក៏ដោយ ក៏វិស័យនេះនៅតែមានសក្តានុពលខ្ពស់ក្នុងការជំរុញ និង ពង្រីកកំណើនសេដ្ឋកិច្ច ក្នុងការជួយកាត់បន្ថយភាពក្រីក្រនៅជនបទដែលជាអាទិភាពខ្ពស់នៅក្នុង យុទ្ធសាស្ត្រចតុកោណ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ប្រការនេះ បញ្ជាក់អោយឃើញថា ការបង្កើនទិន្នផល និង ផលិតភាពកសិកម្ម និង ការជំរុញការអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ជាពិសេស កសិ-ឧស្សាហកម្ម សហគ្រាសធុនតូច និង មធ្យម ពាណិជ្ជកម្ម និងសេវាកម្ម គឺជាប្រការសំខាន់ដើម្បីបង្កើនតំលៃបន្ថែមលើផលិតផល និងស្រូបយកពលកម្មដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស សំរាប់ស្រូបយកពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម ដើម្បីពង្រីកមូលដ្ឋាននៃកំណើន រក្សាចិរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ច ។ កំណើនប្រជាជនសកម្មនៅក្នុងទីផ្សារពលកម្មមានប្រមាណ ៣០ ម៉ឺននាក់ ក្នុង ១ ឆ្នាំ ហើយវិស័យឧស្សាហកម្ម

និង សេវាកម្ម មិនទាន់អាចបង្កើតការងារធ្វើបានគ្រប់គ្រាន់នៅឡើយ ហេតុនេះ ការពង្រីកវិស័យកសិកម្ម នៅតែដើរតួសំខាន់ក្នុងការស្រូបយកកម្លាំងពលកម្ម ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) សេដ្ឋកិច្ចប្រាកដជាអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាម គោលដៅ យុទ្ធសាស្ត្រចតុកោណ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលមានមហិច្ឆតានយោបាយដើម្បីសំរេចអោយបានកំណើនជាមធ្យមប្រមាណ ១០ % ។

៥- ឆ្នាំ ២០០៧ នេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៨,៥% គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ (៦,៥%) តែទាបជាងការអនុវត្តន៍បានជាក់ស្តែង ក្នុងឆ្នាំ ២០០៦ (១០,៤%) កន្លងទៅ ។ នេះជាសេណារីយ៉ូប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេស ដោយសារការរងឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន និង កត្តានិរភាពថវិកា និរភាពគណនីចរន្ត និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ។ តាមសេណារីយ៉ូ នេះ វិស័យឧស្សាហកម្មនឹងមានកំណើនត្រឹមប្រមាណ ១០,៨% ធៀបនឹង ១៧% នៅក្នុងឆ្នាំ ២០០៦ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងមានកំណើនត្រឹមប្រមាណ ១២,៤% ធៀបនឹង ២១,៩% នៅក្នុងឆ្នាំ ២០០៦ ហើយផលិតផលសំណង់ នឹងមានកំណើនត្រឹមប្រមាណ ៩,៨% ធៀបនឹង ១៥,៧% នៅក្នុងឆ្នាំ ២០០៦) វិស័យសេវាកម្មនឹងមាន កំណើនប្រមាណ ៩,៥% ធៀបនឹង ១១,៤% នៅក្នុងឆ្នាំ ២០០៦ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍នឹងមានកំណើនប្រមាណ ១៣% ធៀបនឹង ១៧% នៅក្នុងឆ្នាំ ២០០៦) ។

៦- តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៨ ខាងមុខនេះ អាចនឹងសំរេចបាន ៧% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៤,៥% វិស័យឧស្សាហកម្មនឹងកើនឡើង ៨% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៩% និង ផលិតផលសំណង់នឹងកើនឡើង ៨% និង វិស័យសេវាកម្មនឹងកើនឡើង ៨,៤% ដែលក្នុងនោះ អាជីវកម្មទេសចរណ៍នឹងកើនឡើងប្រមាណ ១០% ។ អតិផរណានឹងស្ថិតនៅក្នុងកំរិតទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់នឹងរក្សាបាននៅក្នុងរង្វង់ ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា

៧- ទោះជាឆ្នាំ ២០០៧ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានទាបជាងឆ្នាំ ២០០៦ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេស លើការអនុវត្តន៍ថវិកាឡើយ ព្រោះកំណើន ៨,៥% នេះ ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ (៦,៥%) ហើយការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និង ប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការអនុវត្តន៍កម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈជាជំហានៗ ប្រកប

ដោយភាពគ្រប់ជ្រុងជ្រោយ និង ទៅតាមលំដាប់លំដោយត្រឹមត្រូវនិងច្បាស់លាស់នោះ នឹងមិនត្រឹមតែធ្វើអោយការអនុវត្តន៍ថវិកាឆ្នាំ ២០០៧ សំរេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុប៉ុណ្ណោះទេ តែថែមទាំងអាចនឹងមានលក្ខណៈល្អប្រសើរជាងឆ្នាំ ២០០៦ ទៀតផង ។ តាមសេណារីយ៉ូនេះ ចំណូលជារួមនឹងកើនឡើងប្រមាណ ១៥% ធៀបនឹងការអនុវត្តន៍ឆ្នាំ ២០០៦ គឺចំណូលក្នុងស្រុកសរុបនឹងសំរេចបាន ១០,៥% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៨,៧% នៃផសស (ចំណូលគយនិង រដ្ឋាករស្មើនឹង ៥,២% និង ចំណូលពន្ធដារស្មើនឹង ២,៧%) ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ១,៧% នៃផសស ។ ចំណាយសរុបអាចនឹងសំរេចបាន ១៤,៣% នៃផសស កើនឡើង ២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៨,៩% នៃផសស កើនឡើង ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៤% នៃផសស កើនឡើង ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ។ ការអនុវត្តន៍ចំណូល និង ចំណាយនេះ អាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,៥% និង ឱនភាពថវិកាសរុបប្រមាណ ៣,៨% នៃផសស ។

៨- ដោយឈរលើមូលដ្ឋាននៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ថវិកាឆ្នាំ ២០០៨ មានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាការបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេស ការបន្តជំរុញការអនុវត្តន៍ យុទ្ធសាស្ត្រចតុកោណ *ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* របស់រាជរដ្ឋាភិបាល ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (PIP) ។
- ធានាបំរើអោយការរៀបចំបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងយន្តការលទ្ធិប្រជាធិបតេយ្យ ។
- បន្តបង្កើនបៀវត្សមូលដ្ឋានប្រមាណ ១៥% និង បន្តជំរុញការអនុវត្តន៍កន្សោមអាទិភាព
- ធានាការអនុវត្តន៍គោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជា÷
